# យើងត្រូវការឱ្យអ្នក ប្រើប្រាស់ឱសថប្រឆាំងមេរោគ ដោយប្រុងប្រយ័ត្ន

អ្នកលក់ដុំ និង អ្នកលក់រាយ

ឱសថប្រឆាំងមេរោគគឺជា **ឱសថសារវន្ត** សម្រាប់ទប់ស្កាត់ និងព្យាបាលជំងឺឆ្លង ទាំងក្នុងខ្លួនមនុស្ស និងទាំងក្នុងខ្លួនសត្វ។

ប៉ុន្តែឱសថប្រឆាំងមេរោគកំពុងបាត់បង់ **ប្រសិទ្ធភាពរបស់វា** ក្នុងល្បឿនមួយកាន់តែលឿន។

- ហានិភ័យដែលភ្នាក់ងារបង្កជំងឺនឹងបង្កើតភាពស៊ាំនឹងឱសថប្រឆាំងមេរោគ មានការកើនឡើងនៅពេលដែលឱសថដ៏មានតម្លៃទាំងនេះ ត្រូវបានគេប្រើលើសលប់ ឬប្រើប្រាស់មិនសមស្រប។ បន្ទាប់ពីបាក់តេរីមានភាពស៊ាំ ឱសថប្រឆាំងមេរោគលែងមានប្រសិទ្ធភាពទៀត និងពុំអាចព្យាបាលជំងឺជានោះឡើយ។ បាតុភូតនេះហៅថា ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (ឬហៅកាត់ជាភាសាអង់គ្លេសថា AMR)។
- ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ គឺជាការគំរាមកំហែងចំពោះសុខភាព និងសុខុមាលភាពរបស់មនុស្ស និងសត្វ មិនថាជាសត្វរស់នៅក្នុងទឹក ឬសត្វរស់នៅលើគោកនោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ការបង្កើតឱសថប្រឆាំងមេរោគថ្មីពុំអាចតាមទាន់ការកើនឡើងនូវភាពស៊ាំនឹងឱសថប្រឆាំងមេរោគដែលកំពុងចរាចរណ៍នោះទេ។
- ការបន្តភាពអាចរកបាន និងប្រសិទ្ធភាពនៃ ឱសថប្រឆាំងមេរោគបច្ចុប្បន្ន មានសារៈសំខាន់យ៉ាងខ្លាំង។ ការប្រើប្រាស់ឱសថដ៏មានតម្លៃទាំងនេះ ប្រកបដោយការទទួលខុសត្រូវ និងដោយមានការប្រុងប្រយ័ត្នទៅតាមស្តង់ដាររបស់អង្គការសុខភាពសត្វពិភពលោក (OIE) ដែលជាអង្គការអន្តររដ្ឋាភិបាល នឹងជួយបន្តឱ្យឱសថទាំងនេះមានប្រសិទ្ធភាព និងនៅតែអាចប្រើប្រាស់បាន សម្រាប់ទាំងសុខភាពមនុស្ស និងសុខភាពសត្វ។




"យើងទាំងអស់គ្នាសុទ្ធតែមានតួនាទីដែលត្រូវបំពេញក្នុងនាមអ្នកជា **អ្នកលក់ ចែកចាយ** ឱសថប្រឆាំងមេរោគ **អាចជួយ ដល់យើងបាន**"

- យើងចាំបាច់ត្រូវរួបរួមគ្នាធានាឱ្យមានការប្រើប្រាស់ ឱសថប្រឆាំងមេរោគប្រកបដោយការទទួលខុសត្រូវ និងប្រុងប្រយ័ត្នលើសត្វ ដើម្បីរក្សា ភាពអាចរកបាន និងប្រសិទ្ធភាពនៃឱសថប្រឆាំងមេរោគទាំងនេះ ដែលជួយការពារសុខភាពនិងសុខុមាលភាពរបស់មនុស្ស និងសត្វ។

- ការឆ្លើយតបចំពោះបញ្ហាមេរោគស៊ាំនឹងឱសថប្រឆាំងមេរោគ គឺជាគោលបំណងអាទិភាពមួយ របស់អង្គការសុខភាពសត្វពិភពលោក (ហៅកាត់ថា OIE)។ តាមរយៈស្តង់ដារអន្តរជាតិរបស់ខ្លួន OIE ជំរុញឱ្យមានការប្រើប្រាស់ ឱសថប្រឆាំងមេរោគប្រកបដោយការទទួលខុសត្រូវ និងប្រុងប្រយ័ត្ន ព្រោះវាមានសារៈសំខាន់ចំពោះសុខភាពនិងសុខុមាលភាពរបស់មនុស្សនឹងសត្វពីសំណាក់គ្រប់តួអង្គពាក់ព័ន្ធនឹងសុខភាពសត្វទាំងអស់ រួមបញ្ចូលទាំងអ្នកផលិតចំណីសត្វ ដែលមានឱសថប្រឆាំងមេរោគផងដែរ។

@ សម្រាប់ព័ត៌មានបន្ថែម៖ **www.oie-antimicrobial.com**

# អ្នកលក់ដុំ និងអ្នកលក់រាយ៖ អ្នកគឺជាអ្នកឃ្លាំមើល

- ដោយសារការចែកចាយឱសថ ដូចជា ឱសថប្រឆាំងមេរោគត្រូវ ធ្វើឡើងប្រកបដោយការទទួលខុសត្រូវ អ្នកគួរដឹងពីសារៈសំខាន់នៃការបន្តរក្សាប្រសិទ្ធភាព និងភាពអាចរកបាននៃឱសថប្រឆាំងមេរោគ។ អ្នកត្រូវដឹងពីសារៈសំខាន់នៃការចែកចាយឱសថប្រឆាំងមេរោគដែលមានគុណភាពខ្ពស់តែប៉ុណ្ណោះ ហើយជានិច្ចកាលត្រូវចែកចាយតែបន្ទាប់ពីមានវេជ្ជបញ្ជាពីបសុពេទ្យតែប៉ុណ្ណោះ។
- ការប្រើប្រាស់ឱសថប្រឆាំងមេរោគ ប្រកបដោយការទទួលខុសត្រូវ និងដោយប្រុងប្រយ័ត្នតម្រូវឱ្យមានការអនុវត្តតាមវិធានការ និងអនុសាសន៍ផ្សេងៗ ក្នុងគោលបំណងលើកកម្ពស់សុខភាព និងសុខុមាលភាពសត្វ ហើយក្នុងពេលជាមួយគ្នា ការបង្ការ ឬកាត់បន្ថយការជ្រើសរើសការកើតឡើង និងការរាលដាលភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។
- ការផ្សព្វផ្សាយលក់ និងការចែកចាយ ឱសថប្រឆាំងមេរោគស្ថិតក្រោមការទទួលខុសត្រូវ និងការត្រួតពិនិត្យរបស់អ្នក។ ភាពជាអ្នកដឹកនាំ និងឥទ្ធិពលរបស់អ្នក បំពេញតួនាទីយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំង នឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគនេះដែលជាការបង្ហាញឱ្យឃើញពីការអនុវត្តន៍ការងារប្រកបដោយវិជ្ជាជីវៈ និងការប្ដេជ្ញាចិត្តរបស់អ្នកចំពោះវិស័យនេះ។

## អ្នកលក់ដុំ និងអ្នកលក់រាយ ត្រូវ៖

១ ប្រើប្រាស់ឱសថ **ដែលមានប្រភពត្រូវបានអនុញ្ញាត** តែប៉ុណ្ណោះ។

២ គ្រប់គ្រងឱសថប្រឆាំងមេរោគដែលប្រើជាមួយសត្វស្របតាមការអនុវត្តន៍ល្អបំផុតពាក់ព័ន្ធនឹង **ការរក្សាទុក និងការដឹកជញ្ជូន**។

៣ ធានាថាការលក់ឱសថប្រឆាំងមេរោគធ្វើឡើងតែ **នៅពេលមានវេជ្ជបញ្ជា ដែលនៅមានសុពលភាព ពីបសុពេទ្យ** តែប៉ុណ្ណោះ រាប់បញ្ចូលទាំងក្នុងករណីដែលមានបទបញ្ជាគ្រប់គ្រងការលក់តាមអ៊ីធឺណែតផងដែរ ប្រសិនបើពាក់ព័ន្ធ។

៤ ធានាថារាល់ផលិតផលទាំងអស់ **មានដាក់ស្លាកសញ្ញាសម្គាល់ត្រឹមត្រូវ**។ ផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់ និងត្រឹមត្រូវអំពីការប្រើប្រាស់ផលិតផល កាលបរិច្ឆេទផុតកំណត់ និងរយៈពេលឈប់ប្រើឱសថនេះ។

៥ គោរពតាម**ក្រមសីលធម៌ ស្តីពីការផ្សាយពាណិជ្ជកម្ម** ស្របតាមគោលការណ៍នៃការប្រើប្រាស់ថ្នាំប្រកបដោយការទទួលខុសត្រូវ និងដោយត្រូវប្រុងប្រយ័ត្ន។

៦ រក្សាទុក **ឯកសារលម្អិត** (អ្នកផ្គត់ផ្គង់ អ្នកចេញវេជ្ជបញ្ជា អ្នកប្រើប្រាស់ ឈ្មោះផលិតផល លេខផលិតផល បរិមាណ និងរយៈពេលដាក់លក់) ដើម្បីអនុញ្ញាតឱ្យគេអាចតាមដានដឹងពីប្រភពរបស់ផលិតផល។

៧ សហការជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ច និង**ផ្តល់ទិន្នន័យលក់លម្អិត** សម្រាប់គោលបំណងពិនិត្យតាមដានលើការប្រើប្រាស់ ឱសថប្រឆាំងមេរោគ។

៨ ធានាថាបុគ្គលិកទាំងអស់ជាបុគ្គលិកដែលមាន**សមត្ថភាពគ្រប់គ្រាន់**។ ចូលរួមនិងផ្តល់ **ការបណ្តុះបណ្តាល** អំពីការរក្សាទុក ការដឹកជញ្ជូន និងការចោលសំណល់ឱសថប្រឆាំងមេរោគដែលមានលក្ខណៈសមស្រប។






Funded by UK Government

WORLD ORGANISATION FOR ANIMAL HEALTH
*Protecting animals, preserving our future*